**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

PHNOM PENH WATER SUPPLY AUTHORITY

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពីការពន្យារពេលរបាយការណ៍ប្រចាំត្រីមាសទី១ ឆ្នាំ២០២០
# របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (រ.ទ.ស.ភ) សូមជម្រាបជូនវិនិយោគិន និងសាធារណជនជ្រាបថា របាយការណ៍ប្រចាំត្រីមាសទី១ ឆ្នាំ២០២០ របស់ រ.ទ.ស.ភ ដែលត្រូវផ្តល់ជូនគណៈកម្មការមូលបត្រកម្ពុជា យ៉ាងយូរត្រឹមថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០ នឹងត្រូវពន្យារពេលហូតដល់ **ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២០** ដោយសារការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ សម្រាប់ឆ្នាំ២០១៩ មានការយឺតយ៉ាវដល់ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២០។ ការយឺតយ៉ាវនៃរបាយការណ៍នេះ ធ្វើឱ្យការរៀបចំព័ត៌មានហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្ន សម្រាប់រយៈពេល ៣ខែ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០ ក៏មានការយឺតយ៉ាវផងដែរ។

ហេតុដូចនេះ របាយការណ៍ប្រចាំត្រីមាសទី១ ឆ្នាំ២០២០ របស់ រ.ទ.ស.ភ ត្រូវពន្យារពេល ដោយសារការអវត្តមាននៃព័ត៌មានហិរញ្ញវត្ថុសង្ខេបបណ្តោះអាសន្ន សម្រាប់រយៈពេល ៣ខែ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០ ដែលជាផ្នែកសំខាន់នៃរបាយការណ៍ប្រចាំត្រីមាស។

អាស្រ័យហេតុនេះ សូមវិនិយោគិន និងសាធារណជនទទួលជ្រាបដោយក្តីអនុគ្រោះ។

ថ្ងៃច័ន្ទ ១៤កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ, ថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២០
**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

អគារ៤៥ ផ្លូវ ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ:(៨៥៥) ២៣ ៦៣៥ ៨០ ៨០ Email: admin@ppwsa.com.kh